**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជសដ |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់ | : | ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១២ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 17-Feb-2012, 14:07
CMS/CFO: Uch Arun

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្ដោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

## សំណើរបស់សហព្រះរាជអាជ្ញា ដើម្បីសុំឲ្យជូនដំណឹងដល់ជនជាប់ចោទ ខៀវ សំផន ស្តីពីផលវិបាកនានានៃការបដិសេធមិនឆ្លើយតបនៅនឹងសំណួរ នៅក្នុងសវនាការ

---

**អ្នកដាក់ឯកសារ:**

**សហព្រះរាជអាជ្ញា:**
លោកស្រី ជា លាង
លោក Andrew CAYLEY

**អ្នកទទួលឯកសារ:**

**អង្គជំនុំជម្រះសាលាដំបូង:**
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យ៉ា សុខន
ចៅក្រមJean-Marc LAVERGNE
ចៅក្រម យូ ឧត្តរា

**សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី:**
ពេជ អង្គ
Elisabeth SIMONNEAU FORT

**ចម្លងជូន:**

**ជនជាប់ចោទ:**
នួន ជា
អៀង សារី
ខៀវ សំផន

**មេធាវីការពារក្តីជនជាប់ចោទ:**
លោក សុន អរុណ
លោក Michiel PESTMAN
លោក Victor Koppe
លោក អាង ឧត្តម
លោក Michael G.KARNAVAS
លោក គង់ សំអុន

លោកស្រី Anta GUISSÉ
លោក Arthur VERCKEN
លោក Jacques VERGÈS

# I. សេចក្ដីផ្ដើម និង អង្គហេតុពាក់ព័ន្ធ

១- អនុលោមតាមវិធាន២១(១), ៨៥ និង៩០ នៃវិធានផ្ទៃក្នុង និងដើម្បីជាផលប្រយោជន៍ដល់សិទ្ធិរបស់ជនជាប់ចោទ និងដល់ប្រសិទ្ធភាពក្នុងការចាត់ចែងរៀបចំសវនាការ សហព្រះរាជអាជ្ញាសូមស្នើដល់អង្គជំនុំជម្រះសាលាដំបូង ("អង្គជំនុំជម្រះ") ដើម្បីឱ្យណែនាំដល់ ខៀវ សំផន ថា៖
១) សេចក្ដីសន្និដ្ឋានដោយផ្ទាល់មាត់របស់គាត់នៅចំពោះមុខអង្គជំនុំជម្រះ គឺមិនទំនងជាត្រូវបានយល់ព្រមថាជាទម្ងន់ជាភស្តុតាងដ៏មានសារសំខាន់ (significant evidentiary weight) នោះទេ លុះត្រាតែគាត់សុខចិត្តយល់ព្រមឱ្យអង្គជំនុំជម្រះនិងភាគីនានាធ្វើការសួរដេញដោល។ ២) ហើយជាងនេះទៅទៀត ការទាញសេចក្ដីសន្និដ្ឋានជាអវិជ្ជមានអាចនឹងត្រូវបានធ្វើឡើងប្រឆាំងនឹងរូបគាត់ បើគាត់បដិសេធមិនព្រមឆ្លើយនឹងសំណួរ។

២- សំខាន់ជាមូលដ្ឋាន គឺជាសេចក្ដីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាដែលថា ចាប់តាំងពី ខៀវ សំផន មិនបានអនុវត្តនូវសិទ្ធិរបស់ខ្លួន ក្នុងការនៅស្ងៀមមិនឆ្លើយ និងសំរេចចិត្តក្នុងការផ្ដល់ភស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះមក មិនមានការបើកឱ្យគាត់បដិសេធមិនឆ្លើយទៅនឹងសំណួរនានាពីអស់លោកលោកស្រីចៅក្រម និងពីភាគីនានាឡើយ។ ក្នុងពេលដែលច្បាប់និងវិធានផ្សេងៗរបស់កម្ពុជាមិនបាននិយាយដល់អំពីបញ្ហានេះនោះ គោលការណ៍នានាដែលបានបង្កើតឡើងនៅក្នុងកំរិតអន្តរជាតិ បានបញ្ជាក់យ៉ាងច្បាស់ថា ក្នុងករណីបើសិនជា ជនជាប់ចោទសម្រេចចិត្តជ្រើសរើសថាផ្ដល់ភស្តុតាងហើយនោះ ការបដិសេធណាមួយពីសំណាក់ជនជាប់ចោទមិនឆ្លើយតបនឹងសំណួរផ្ដល់ភស្តុតាងអាចនាំឱ្យមាន ការទាញសេចក្ដីសន្និដ្ឋានជាអវិជ្ជមាននៅក្នុងការធ្វើការសន្និដ្ឋានវាយតម្លៃរបស់តុលាការសាលាដំបូង ទៅលើភស្តុតាងដែលទាក់ទងនឹងជនជាប់ចោទនៅក្នុងតុលាការ។

៣- ចាប់តាំងពីមុនពេលចាប់ផ្ដើមការជំនុំជម្រះក្ដី (well before) ខៀវ សំផន បានបញ្ជាក់យ៉ាងច្បាស់ថា គាត់មានបំណងចង់ចូលរួមនៅក្នុងដំណើរការនីតិវិធីទាំងនេះដោយធ្វើការផ្ដល់ភស្តុតាងនិងថា គាត់មិនអនុវត្តសិទ្ធិនៅស្ងៀមមិនឆ្លើយរបស់គាត់ទេ។ នៅក្នុងការដាក់សារណាមួយដែលពាក់ព័ន្ធទៅនឹងបញ្ហាស្ដីពីអង្គហេតុនានាដែលត្រូវបានយល់ព្រម មេធាវីការពារក្ដីរបស់ ខៀវសំផន បានថ្លែងថា៖

> *"ក្នុងខណៈពេលដែល ខៀវ សំផន មិនមានបំណងចង់ប្រកាន់យកនូវជំហរណាមួយចំពោះអង្គហេតុណាមួយដូចដែលបានរៀបរាប់នៅក្នុងដីកាដំណោះស្រាយនោះ ទោះបីជា*

*យ៉ាងណាក្តីក៏គាត់នឹងរួមចំណែកយ៉ាងសកម្មដល់កិច្ចការស្វែងរកយុត្តិធម៌ដោយផ្តល់ជូននូវអង្គហេតុនានាតាមលំនាំអត្ថបទរបស់គាត់នៅក្នុងសវនាការ ដើម្បីជាផលប្រយោជន៍ដល់* ***ការពិត****ដែលទាក់ទងនឹងប្រវត្តិសាស្ត្រនិងច្បាប់ សម្រាប់សហគមន៍អន្តរជាតិ និងសម្រាប់ប្រជាជនកម្ពុជា"*[1] (ការសង្កត់ន័យតាមសំដីដើមដោយអក្សរទ្រេត)

៤- នៅក្នុងពេលចាប់ផ្តើមដំណើរការនីតិវិធីទាក់ទងនឹងភស្តុតាង ក្នុងខែវិច្ឆិកាឆ្នាំ២០១១ ជនជាប់ចោទបានផ្តល់ចម្លើយបន្ទាប់ពីការធ្វើសេចក្តីសន្និដ្ឋានបើកការចោទប្រកាន់របស់សហព្រះរាជអាជ្ញា ដូចដែលមានចែងនៅក្នុងវិធាន៨៩*ស្ទួន* នៃវិធានផ្ទៃក្នុង[2]។ សហព្រះរាជអាជ្ញាមិនបានប្រកាន់ជំហរថានេះគឺស្មើនឹងការ (this amounted to) ផ្តល់ភស្តុតាងនោះឡើយ។ ក៏ប៉ុន្តែ ដូចដែលបានបង្ហាញជូនដោយមានឧទាហរណ៍បញ្ជាក់ផងដូចខាងក្រោម នៅក្នុងដំណើរការនីតិវិធីជាបន្តបន្ទាប់មកទៀត ជនជាប់ចោទបានបញ្ជាក់ថា គាត់នឹងផ្តល់ភស្តុតាង ហើយជាការពិតគឺគាត់បានធ្វើដូច្នោះមែន។

៥- បញ្ហាអំពីបំណងរបស់ជនជាប់ចោទដែលទាក់ទងនឹងការផ្តល់សក្ខីកម្មត្រូវបានលើកឡើងដោយសហព្រះរាជអាជ្ញាជាតិ នៅពេលធ្វើសេចក្តីសន្និដ្ឋានបញ្ចប់សេចក្តីសន្និដ្ឋានបើកការចោទប្រកាន់កាលពីថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១១។ នៅពេលដែល ខៀវសំផន និងមេធាវីរបស់ខ្លួន ត្រូវបានស្នើសុំឱ្យថ្លែងបញ្ជាក់អំពីជំហររបស់ខ្លួននោះ មានការនិយាយឆ្លើយឆ្លងគ្នាទៅវិញទៅមកតាមពាក្យពេចន៍ដូចខាងក្រោមនេះ៖

***[ ប្រធានអង្គជំនុំជម្រះ]***

*តើមេធាវីការពារក្តីរបស់ ខៀវ សំផន មានបំណងដើម្បីចង់បញ្ជាក់ណាមួយឱ្យបានច្បាស់អំពីរឿងនេះដែរឬទេ?*

***លោក គង់ សំអុនៈ***

*សូមជំរាបក្រុមប្រឹក្សាជំនុំជម្រះ ! លោក ខៀវ សំផន នឹងឆ្លើយនូវសំណួរ បាទ។ សូមអរគុណ។*

***ប្រធានអង្គជំនុំជម្រះ***

---

[1] ឯកសារលេខ **E9/17** អង្គហេតុដែលមិនមានការប្រឆាំងតវ៉ា ចុះថ្ងៃទី២៣ មីនា២០១១, ទំព័រ២។ សូមអានផងដែរ ឯកសារលេខ **E1/2.1** ប្រតិចារិកនៃការប្រជុំត្រៀមរៀបចំសវនាការ ចុះថ្ងៃទី៥ មេសា ឆ្នាំ២០១១ , ទំព័រ ២០។

[2] **E1/15.1** ប្រតិចារិក ចុះថ្ងៃទី២៣ ខែវិច្ឆិកា, ទំព័រ ៤៨: ៩-២៣។

*បាទ អរគុណនូវការផ្ដល់ព័ត៌មាននេះ។*

***លោក ខៀវ សំផន:***

*ខ្ញុំគ្រាន់តែសូមបញ្ជាក់ថា នាពេលវេលាខាងក្រោយនេះ ខ្ញុំមិនទាន់ឆ្លើយ ខ្ញុំសូមបញ្ជាក់ថា ខ្ញុំមិនទាន់ឆ្លើយ។ ខ្ញុំចង់ស្ដាប់ព្រះរាជអាជ្ញាសិន ប៉ុន្តែខ្ញុំនឹងឆ្លើយនៅពេលដែលសមស្រប។ ពីព្រោះ លោកព្រះរាជអាជ្ញាជាអ្នកផ្ដល់ភស្តុតាង។ មិនមែនខ្ញុំជាអ្នកត្រូវផ្ដល់ភស្តុតាងពីអំពើស្មោះត្រង់របស់ខ្ញុំទេ។ លោកព្រះរាជអាជ្ញាចង់ចោទអ្វីខ្ញុំ បង្ហាញឱ្យច្បាស់សិនមក ខ្ញុំនឹងមើលឱ្យអស់សិន ។ រួចដល់ពីហ្នឹងទៅខ្ញុំនឹងឆ្លើយហើយ ខ្ញុំនឹងបញ្ជាក់តែប៉ុណ្ណឹងទេ[3] ។ សូមអរគុណ។*

៦- មុននេះ នៅក្នុងពេលសវនាការដដែលនេះ ខៀវ សំផន បានថ្លែងថា៖

*ទោះជាអ្វីដែលខ្ញុំទើបតែនិយាយយ៉ាងនេះក៏ដោយ យ៉ាងណាក៏ដោយ ខ្ញុំនៅតែសង្ឃឹមថា យ៉ាងហោចណាស់តុលាការនេះ ក៏អាចជាឱកាសឱ្យខ្ញុំបានពន្យល់ដល់ជនរួមជាតិយើង ដើម្បីយល់ថា ហេតុម្ដេចបានជាខ្ញុំ ដែលជាអ្នកកាន់តំណែងមួយខ្ពស់ជាផ្លូវការ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យហើយខ្ញុំនៅតែថា មិនដែលបានចូលរួមសម្រេចកិច្ចការអ្វីធំដុំសោះ ហើយមិនបានដឹងទាល់តែសោះអំពីអ្វីដែលបានកើតមាន នៅក្នុងប្រទេសយើងពីពេលនោះ។ ដោយព្រមទាំងរឿងគួរឱ្យរន្ធត់ ដូចដែលលោកស្រីព្រះរាជអាជ្ញាបានលើកឡើង កាលពីថ្ងៃច័ន្ទ ២១ វិច្ឆិកា។*

*ខ្ញុំបានស្បថនៅចំពោះមុខប្រទេសជាតិរបស់ខ្ញុំថា ខ្ញុំនឹងខំប្រឹងឱ្យអស់លទ្ធភាពដើម្បីចូលរួមនៅក្នុងដំណើរការនីតិវិធីនេះ ហើយខ្ញុំនឹងធ្វើទៅតាមសម្បថនោះ[4] ។*

៧- កាលពីថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១១ នៅពេលដែល អស់លោក-លោកស្រីចៅក្រម(នៃអង្គជំនុំជម្រះ) កំពុងតែអនុវត្តការសួរដេញដោលជនជាប់ចោទទាក់ទងនឹងផ្នែកស្ដីពីប្រវត្តិដើមដែលមាននៅក្នុងដីកាដំណោះស្រាយ នួន ជា បានសម្រេចចិត្តធ្វើការឆ្លើយតបនឹងសំនួរផ្សេងៗ ចំណែកឯ អៀង សារី បានធ្វើជាសេចក្ដីថ្លែងមួយដែលបញ្ជាក់យ៉ាងច្បាស់និងយ៉ាងជាក់លាក់ថា គាត់នឹងអនុវត្តសិទ្ធិរបស់គាត់ក្នុងការនៅស្ងៀមមិនឆ្លើយតប ហើយនឹងមិនធ្វើការឆ្លើយតបទៅនឹងសំនួរណាមួយឡើយនៅក្នុងអម្លុង

---

[3] **E1/15.1** ប្រតិចារិក ចុះថ្ងៃទី២៣ ខែវិច្ឆិកា, ទំព័រ ៤៨: ៩-២៣។

[4] **E1/15.1** ប្រតិចារិក ចុះថ្ងៃទី២៣ ខែវិច្ឆិកា, ទំព័រ១៧-១៨។

ពេលនៃសវនាការជំនុំជម្រះក្ដីនេះទាំងមូល[5]។ ចំណែកឯ ខៀវ សំផន វិញ បានសម្រេចចិត្តថា នឹងផ្តល់ភស្តុតាងជូន ប៉ុន្តែបានបដិសេធមិនឆ្លើយតបនឹងសំនួរផ្សេងៗពី អស់លោក-លោកស្រីចៅក្រម និងពីភាគីនានា។ ភ្លាមៗនោះ នៅមុនពេលអង្គជំនុំជម្រះសួរសំនួរអំពី ខៀវ សំផន មេធាវីការពារក្តីរបស់គាត់បានថ្លែងដូចខាងក្រោមនេះ៖

> *ដូចលោកចៅក្រម Lavergne [ខៀវ សំផន] មានបំណងចង់ប្រតិកម្មទៅនឹងធ្វើសេចក្ដីអត្ថាធិប្បាយទៅលើកថាខណ្ឌនានា ដីកាដំណោះស្រាយដែលត្រូវបានអាននៅក្នុងអង្គជំនុំជម្រះនេះ ដែលជាផ្នែកស្ថិតនៅក្នុងផ្នែកដំបូងនៃសវនាការ។ ម្យ៉ាងទៀត ទាក់ទងទៅនឹងសំនួរដែលអាចចោទសួរចំពោះគាត់ គាត់មានបំណងចង់ប្រើប្រាស់នូវសិទ្ធិរបស់គាត់ដើម្បីនៅស្ងៀមមិនឆ្លើយតបទេ ក្នុងពេលនេះរង់ចាំការបង្ហាញជូនពីខាងអយ្យការនូវភស្តុតាងនានាសម្រាប់ផ្នែកទាងឡាយណានៃសវនាការដែលទាក់ទងនិងយើង។ ហេតុនេះ ចំពោះមុខនេះ គាត់និងមានប្រតិកម្មចំពោះតែផ្នែកទាំងឡាយណានៃដីកាដំណោះស្រាយដែលទាក់ទងនឹងផ្នែកនេះនៃករណីរឿងតែប៉ុណ្ណោះ[6]។*

៨- នៅពេលដែលមេធាវីប្រើនូវប្រយោគ "សិទ្ធិដើម្បីនៅស្ងៀមមិនឆ្លើយតប" នេះគឺជាការច្បាស់ណាស់គឺមិនមែនជាការទាញសេចក្តីសន្និដ្ឋានណាមួយអំពិសិទ្ធិក្នុងការនៅស្ងៀមមិនឆ្លើយតបដែលទាក់ទងទៅនឹងបទចោទប្រកាន់នានានោះទេ ប៉ុន្តែផ្ទុយទៅវិញ គឺជាសញ្ញាបញ្ជាក់ថា ខៀវ សំផន បានមានបំណងជាដំបូងចង់ផ្តល់នូវភស្តុតាងរបស់គាត់ផ្ទាល់ ហើយនិងឆ្លើយតបទៅនឹងសំនួរនានានៅដំណាក់កាលក្រោយទៀតនៃសវនាការ។ គោលជំហរនោះគឺជាការច្បាស់ណាស់ បន្ទាប់ពីការនិយាយឆ្លើយឆ្លងគ្នា រវាងប្រធានអង្គជំនុំជម្រះ និង ខៀវ សំផន នៅក្នុងសវនាការដដែលនេះ៖

> ***ប្រធានអង្គជំនុំជម្រះ***
> *សូមអរគុណ!*
> *ឥឡូវនេះ តើលោកមានបំណងប្រើប្រាស់សិទ្ធិរបស់លោកក្នុងការនៅស្ងៀមមិនឆ្លើយឬមួយក៏លោកចង់ឆ្លើយតបនឹងសំនួរដោយអង្គជំនុំជម្រះក៏ដូចជាដោយភាគីនានានៅក្នុងទូទាំងអម្លុងពេលដំណើរការនីតិវិធីទាំងមូល ឥឡូវនេះ?*

---

[5] **E1/21.1** ប្រតិចារិក ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១១ , ទំព័រ ៥៩:កថាខណ្ឌទី ១១-១៦។

[6] **E1/15.1** ប្រតិចារិក ចុះថ្ងៃទី២៣ ខែវិច្ឆិកា , កថាខណ្ឌទី៦១-៦២។

***លោក ខៀវ សំផនៈ***

*ខ្ញុំសូមស្នើយោបល់មួយ លោកប្រធាន។ខ្ញុំសូមធ្វើអត្ថាធិប្បាយទៅលើកថាខណ្ឌទាំងឡាយនៃដីកាដំណោះស្រាយដែលត្រូវបានអានជូនកាលពីថ្ងៃទី៥ខែធ្នូ។ ប៉ុន្តែ ខ្ញុំយល់ទាំងស្រុងថា នេះគឺជាសវនាការរបស់ខ្ញុំ ហើយខាងអយ្យការពួកគាត់មានការយល់ឃើញតាមទស្សនៈរបស់ពួកគាត់ទាក់ទងនឹងកថាខណ្ឌទាងនោះ ហើយជាពិសេសការយល់របស់ពួកគាត់ទៅលើធាតុផ្សំនៃបរិបទដែលទាក់ទងទៅនឹងដីកាដំណោះស្រាយ ហើយខ្ញុំធ្វើការជំទាស់យ៉ាងខ្លាំងចំពោះការយល់ឃើញរបស់ពួកគាត់។ ហើយតាមពិតអយ្យការត្រូវតែបង្ហាញភស្តុតាងឱ្យឃើញថា ហួសពីវិមតិសង្ស័យ។*

*....*

***<u>ហេតុដូចនេះហើយបានជាខ្ញុំកំពុងសូមស្នើយោបល់</u>*** *ដោយមានការនុញ្ញាតពីលោកប្រធានពីអង្គជំនុំជម្រះ---* ***<u>ខ្ញុំសូមជំរាបជូនអង្គជំនុំជម្រះអំពីការយល់ឃើញរបស់ខ្ញុំ</u>*** *ជាពិសេសលើបរិបទបរិបទប្រវត្តិសាស្ត្រ* ***<u>ហើយខ្ញុំនឹងឆ្លើយតបទៅនឹងសំណួរតែនៅពេលណា ដែលខ្ញុំអាចនឹងសួរដេញដោលបានលើភស្តុតាងដែលខាងអយ្យការ</u>****បានបង្ហាញជូនដើម្បីគាំទ្រចំពោះការពោលអះអាងតែប៉ុណ្ណោះ។ តើលោកប្រធានអនុញ្ញាតឱ្យខ្ញុំដំណើរការតាមរបៀបនេះដែរឬទេ?[7] ។សូមអរគុណ។*
(ការសង្កត់ន័យបន្ថែមដោយអក្សរទ្រេត)

៩- នៅពេលសុំឱ្យបញ្ជាក់បន្ថែមអំពីជំហររបស់គាត់ ខៀវ សំផន ជាថ្មីម្តងទៀតបានអះអាងថា គាត់មិនប្រើសិទ្ធិនៅស្ងៀមមិនឆ្លើយតបទេ ប៉ុន្តែផ្ទុយទៅវិញ គាត់ជ្រើសរើសពេលវេលាដែលគាត់នឹងឆ្លើយតបទៅនឹងសំណួរផ្សេងៗដូចតទៅៈ

*លោកប្រធាន លោក លោកស្រីចៅក្រមជាទីគោរព, ខ្ញុំសូមមានយោបល់ទាក់ទងនឹងកថាខ័ណ្ឌមួយដែលបានអានដោយអង្គជំនុំជម្រះកាលពីថ្ងៃចន្ទ ទី៥ ខែធ្នូ ប៉ុន្តែខ្ញុំនៅរក្សាសិទ្ធិរបស់ខ្ញុំ* ***<u>មិនឆ្លើយតបទៅនឹងសំណួរណាមួយដែលបានសួរសម្រាប់ពេលនេះ</u>*** *-- សំណួរពីភាគីណាមួយ--* ***<u>ពីព្រោះខ្ញុំត្រូវរង់ចាំរហូតទាល់តែការចោទប្រកាន់នេះមានភ័ស្តុតាង</u>*** *គាំទ្រទស្សនៈរបស់ពួកគាត់ ពីព្រោះខ្ញុំគិតថា ទស្សនៈទាំងនេះផ្ទុយពីទស្សនៈរបស់ខ្ញុំ[8] ។* (សង្កត់ធ្ងន់ត្រង់អក្សរដិតធំមានគូសបន្ទាត់ពីក្រោម)

[7] **E1/21.1** ប្រតិចារិក ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១១, កថាខណ្ឌទី ៦៧-៦៨។

[8] **E1/21.1** ប្រតិចារិក ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១១, ទំព័រ ៦៩: ៥-១១។

១០- បន្ទាប់មក គាត់ក៏បានចាប់ផ្ដើមធ្វើសេចក្ដីថ្លែងយ៉ាងលម្អិតមួយអំពីអង្គហេតុដែលបានចោទប្រកាន់ ដូចមានចែងនៅក្នុងផ្នែកប្រវត្តិសាស្ត្រនៃដីកាដំណោះស្រាយ[9]។ តាមរយៈការធ្វើដូច្នេះ គាត់បានផ្ដល់នូវសក្ខីកម្មដ៏មានសារសំខាន់ទៅតាមរបៀបផ្ទាល់ខ្លួនរបស់គាត់អំពីព្រឹត្តិការណ៍ផ្សេងៗ និងដោយមានការអនុញ្ញាតរបស់អង្គជំនុំជម្រះ គាត់បានពន្យារពេលនៃការសួរដេញដោលរបស់គាត់ដោយគូភាគី រហូតដល់ពេលក្រោយទៀត។

១១- នៅថ្ងៃទី១២ ខែមករា ឆ្នាំ២០១២ គឺនៅពេលដែលវគ្គនៃសវនាការអំពីប្រវត្តិសាស្ត្រ ត្រូវចូលមកដល់ដំណាក់កាលចុងក្រោយ មេធាវីក្រុម Lavergne បានសួរ ខៀវ សំផន ឱ្យឆ្លើយនឹងសំណួរមួយឈុត (ឬស្នើឱ្យគាត់មានយោបល់) ទាក់ទងនឹងឯកសារជាក់លាក់មួយចំនួនដែលមាននៅក្នុងសំណុំរឿង ដែលអង្គជំនុំជម្រះពិចារណាថា ពាក់ព័ន្ធ។ មកដល់ត្រង់ចំណុចនេះ មេធាវីការពារក្ដី ខៀវ សំផន បានបញ្ជាក់ថា "លោក ខៀវ សំផន នៅតែរក្សាមិនឆ្លើយតបទៅនឹងសំណួរណាមួយឡើយ"[10]។ ជាថ្មីម្ដងទៀត ខៀវ សំផន បានបញ្ជាក់ថា គាត់មានចេតនានឹងឆ្លើយទៅនឹងសំណួរផ្សេងៗនៅពេលក្រោយៈ

*"បើសិនជាសំណួរពាក់ព័ន្ធនឹងប្រវត្តិសាស្ត្ររបស់កម្ពុជាប្រជាធិបតេយ្យ ខ្ញុំប្រហែលជានឹងមិនឆ្លើយទៅនឹងសំណួរនេះទេ។ ខ្ញុំបានបញ្ជាក់ច្បាស់ហើយថា ខ្ញុំនឹងមិនឆ្លើយទៅនឹងសំណួរណាមួយទេ; គឺគ្រាន់តែរង់ចាំរហូតដល់ពេលសហព្រះរាជអាជ្ញា ដាក់សំណួរទាំងអស់របស់គាត់សិន ហើយខ្ញុំជឿថា ជំហរនេះបានបញ្ជាក់ច្បាស់ហើយៗមេធាវីរបស់ខ្ញុំ ក៏បានបញ្ជាក់បន្ថែមអំពីគោលជំហររបស់ខ្ញុំនេះដែរ"*[11]។

១២- បន្ទាប់មក គាត់បានឆ្លើយនឹងសំណួររបស់មេធាវីក្រុម Lavergne ទាក់ទងនឹងចម្លើយពីមុនមួយអំពីសមាជិកភាពរបស់គាត់ក្នុងគណៈមជ្ឈិម បកក[12] និងបានចាប់ផ្ដើមអះអាងអំពីភាពអ្នកនិពន្ធនៃសៀវភៅមួយក្បាលដែលបានដាក់នៅក្នុងសំណុំរឿង[13]។ ខៀវ សំផន និងមេធាវីការពារក្ដីរបស់គាត់ បន្ទាប់មក ក៏ត្រូវបានសួរថាតើ ជនជាប់ចោទមានចេតនាចង់ឆ្លើយនឹងសំណួរផ្សេងៗដែលជាផ្នែកនៃវគ្គបន្ទាប់

---

[9] **E1/21.1** ប្រតិចារិក ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១១, ទំព័រ ៧០-៨០។

[10] **E1/26.1** ប្រតិចារិក ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១២, ទំព័រ ៥៥: ៦-៨។

[11] **E1/26.1** ប្រតិចារិក ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១២, ទំព័រ ៥៦: ២-៧។

[12] **E1/26.1** ប្រតិចារិក ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១២, ទំព័រ ៦៧: ១៧-២៥។

[13] **E1/26.1** ប្រតិចារិក ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១២, ទំព័រ ៧១: ១៨-២២។

នៃសវនាការជំនុំជម្រះដែរឬទេ (ពាក់ព័ន្ធនឹងរចនាសម្ព័ន្ធរដ្ឋបាល)[14]។ ជាការឆ្លើយតប មេធាវីការពារក្តីបាននិយាយថា "គាត់ជឿថា នៅពេលនោះ លោក ខៀវ សំផន នឹងត្រៀមខ្លួនរួចស្រេចដើម្បីឆ្លើយតបទៅនឹងសំណួរផ្សេងៗ"[15]។ ចំពោះខ្លួនគាត់វិញ ខៀវ សំផន បាននិយាយថា គាត់មិនអាចបញ្ជាក់បានថាតើ គាត់នឹងឆ្លើយ ឬមិនឆ្លើយនឹងសំណួរ"[16]។

១៣- ក្នុងខណៈដែលមេធាវីការពារក្តី ខៀវ សំផន បានយោងម្តងម្កាលអំពីការប្រើសិទ្ធិនៅស្ងៀមមិនឆ្លើយតបរបស់ជនជាប់ចោទ[17] សហព្រះរាជអាជ្ញាសន្និដ្ឋានថា ការណ៍នេះមិនមែនជាជំហរ*ផ្លូវច្បាប់*ត្រឹមត្រូវទាក់ទិននឹង ខៀវ សំផន ឡើយ។ ជនជាប់ចោទបានលះបង់សិទ្ធិនៅស្ងៀមមិនឆ្លើយតបរបស់គាត់តាមរយៈ ១) ការបញ្ជាក់ថា គាត់មានចេតនាចូលរួមយ៉ាងសកម្មនៅក្នុងសវនាការជំនុំជម្រះនេះ តាមការបង្ហាញអង្គហេតុផ្ទាល់ខ្លួនរបស់គាត់នៅសវនាការ និងផ្តល់ការពន្យល់ផ្សេងៗទាក់ទិននឹងសមាជិកភាពរបស់គាត់នៅក្នុងថ្នាក់ដឹកនាំ បកក/កម្ពុជាប្រជាធិបតេយ្យ; ២) ការផ្តល់ភ័ស្តុតាងពិតប្រាកដនៅក្នុងអំឡុងនៃកិច្ចដំណើរការនីតិវិធី និង៣) ការបញ្ជាក់ថា គាត់នឹងឆ្លើយទៅនឹងសំណួរផ្សេងៗរបស់ចៅក្រម និងគូភាគី នៅពេលណាគាត់បានឮអំពីភ័ស្តុតាងនោះ។

១៤- ការសម្រេចចិត្តរបស់ជនជាប់ចោទ (យ៉ាងជាក់ស្តែង) មិនឆ្លើយតបទៅនឹងសំណួរផ្សេងៗនៅដំណាក់កាលណាមួយនាពេលក្រោយ ហាក់ដូចជាបង្ហាញនូវចេតនាធ្វើឱ្យរូបគាត់ស្ថិតក្នុងជំហរមួយដ៏ល្អបំផុតក្នុងការឆ្លើយតបទៅនឹងភ័ស្តុតាងផ្សេងៗ។ ការណ៍នេះ គឺជាការសម្រេចចិត្តដ៏មានល្បិចកល ដែលបើតាមការសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា មានការពាក់ព័ន្ធតិចតួចប៉ុណ្ណោះក្នុងការស្វែងរកការពិត (ដែលជនជាប់ចោទបាននិយាយថា ជាគោលដៅមួយរបស់គាត់) ប៉ុន្តែវាស្ថិតនៅក្រោមសិទ្ធិរបស់ជនជាប់ចោទដ៏ឥតខ្ចោះដែលត្រូវប្រកាន់យក។ ទោះជាយ៉ាងណាក្តី ការអភិវឌ្ឍន៍ដូចបានរៀបរាប់ពីខាងលើ ក៏បញ្ជាក់ផងដែរថា គេមានលទ្ធភាពខុសគ្នាមួយដែលថា ជនជាប់ចោទនឹងបន្តផ្តល់ភ័ស្តុតាងតាមរយៈការធ្វើសេចក្តីថ្លែងផ្សេងៗនៅខណៈដែលការជំនុំជម្រះត្រូវបានលាតត្រដាង ប៉ុន្តែ បើមិនដូច្នេះទេ គាត់នឹងបដិសេធមិនឆ្លើយតបទៅនឹងសំណួរណាមួយទោះជាសំណួរអ្វីក៏ដោយ។

[14] **E1/26.1** ប្រតិចារិក ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១២, ទំព័រ ៧៨-៨០។

[15] **E1/26.1** ប្រតិចារិក ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១២, ទំព័រ ៨០: ២០-២២។

[16] **E1/26.1** ប្រតិចារិក ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១២, ទំព័រ ៨២: ១០-១៤។

[17] សូមមើលសេចក្តីយោងក្នុងអត្ថបទខាងលើ និងសូមមើលផងដែរ ឯកសារ **E1/26.1** ។ប្រតិចារិក, ១២ មករា ២០១២ ត្រង់ទំព័រ៧៤: ២៤-២៥។

ដោយសារហេតុផលនេះហើយទើបសហព្រះរាជអាជ្ញាសន្និដ្ឋានថា ជនជាប់ចោទពេលនេះត្រូវតែប្រាប់ឲ្យដឹងអំពីវិបាកផ្សេងៗដែលបណ្តាលមកពីសេចក្តីសម្រេចណាមួយ សម្រាប់ការវាយតម្លៃចំពោះភ័ស្តុតាងប្រឆាំងនឹងរូបគាត់។

## សេចក្តីសន្និដ្ឋានដោយសង្ខេបអំពីច្បាប់ជាធរមាន

១៥- វិធានផ្ទៃក្នុង និងច្បាប់នីតិវិធីរបស់កម្ពុជា មិនមានចែងទេអំពីបញ្ហានៃ (១) ទម្ងន់នៃភ័ស្តុតាងដែលត្រូវផ្តល់ចំពោះចម្លើយ ដែលបានធ្វើឡើងដោយជនជាប់ចោទដែលបដិសេធមិនឆ្លើយទៅនឹងសំណួរផ្សេងៗធ្វើដោយអង្គជំនុំជម្រះ ឬគូភាគី; និង(២) ការពិចារណាផ្ទុយពីបំណង ដែលអាចនឹងកើតចេញពីសេចក្តីសម្រេចរបស់ជនជាប់ចោទ ដោយសារការបដិសេធមិនឆ្លើយតបទៅនឹងសំណួរផ្សេងៗ នៅពេលណាខ្លួនបានជ្រើសយកការឆ្លើយបំភ្លឺ។ ទន្ទឹមនេះដែរ អង្គជំនុំជម្រះអាចស្វែងរកគោលការណ៍ណែនាំពីវិធានស្តីពីនីតិវិធីដែលបានបង្កើតនៅថ្នាក់អន្តរជាតិ[18]។

### ក. តម្លៃជាភស្តុតាងនៃចម្លើយដែលគ្មានការធ្វើតេស្តសាកល្បង

១៦- វិធានផ្ទៃក្នុងមានចែងអំពីការឆ្លើយតបដោយជនជាប់ចោទក្នុងពេលបើក និងពេលបិទការជំនុំជម្រះ[19]។ គេគ្មានបទប្បញ្ញត្តិសម្រាប់ការឆ្លើយផ្សេងៗទៀតដោយជនជាប់ចោទទេ ក្រៅតែអំពីតាមរយៈការធ្វើសក្ខីកម្មនៅពេលកិច្ចដំណើរការនីតិវិធីភ័ស្តុតាងចាប់ផ្តើម[20]។

១៧- វិធានរបស់តុលាការ ICTY បានបង្កើតបទប្បញ្ញត្តិស្តីពីចម្លើយដែលគ្មានការធ្វើសម្បថធ្វើឡើងដោយជនជាប់ចោទណាម្នាក់ក្នុងអម្លុងនៃដំណើរការជំនុំជម្រះ។ វិធាន៨៤*ស្ទួន* នៃវិធានស្តីពី នីតិវិធី និងភ័ស្តុតាង របស់តុលាការ ICTY ("ICTY RPE") ចែងថា:

---

[18] មាត្រា៣៣ថ្មី, ច្បាប់ អ.វ.ត.ក។

[19] វិធាន ៨៩*ស្ទួន* (២) និង ៩៤(១)។

[20] វិធាន ៩០ នៃវិធានផ្ទៃក្នុង។ សូមមើលផងដែរវិធាន៨៩*ស្ទួន* (២): "នៅមុនពេលសួរចម្លើយជនជាប់ចោទ..."។

*(ក) បន្ទាប់ពីសេចក្តីសន្និដ្ឋានបើកការចោទប្រកាន់របស់គូភាគីរួចមក ឬ ប្រសិនមេធាវីការពារក្តីជ្រើសរើសយកការពន្យារពេលក្នុងការធ្វើសេចក្តីសន្និដ្ឋានទៅពេលបើកការជំនុំជម្រះ ដោយអនុលោមតាមវិធាន៨៤ និងបន្ទាប់ពីសេចក្តីសន្និដ្ឋានបើកការចោទប្រកាន់របស់រដ្ឋអាជ្ញា បើសិនជាមាន និងប្រសិនបើអង្គជំនុំជម្រះសាលាដំបូងសម្រេចដូច្នេះ ហើយបើសិនជាជនជាប់ចោទមានបំណងចង់ធ្វើដូច្នេះ ជនជាប់ចោទអាចធ្វើការឆ្លើយតបណាមួយបាន តែត្រូវស្ថិតក្រោមការត្រួតពិនិត្យរបស់អង្គជំនុំជម្រះសាលាដំបូង។*

*(ខ) អង្គជំនុំជម្រះសាលាដំបូង ត្រូវសម្រេចអំពីតម្លៃភស្តុតាងនៃចម្លើយតបនោះ បើសិនជាមាន។*

១៨- នៅក្នុងការអនុវត្ត ការថ្លែងរបស់វិធាន *៨៤ស្ទួន* គឺ "ជាទូទៅ បានផ្តល់នូវទម្ងន់ក្នុងក្រិតណាមួយស្រាលជាងសក្ខីកម្មដែលបានផ្តល់នៅក្រោមសម្បថ ដែលត្រូវជាប្រធានបទនៃការសួរដេញដោលសាក្សីរបស់ភាគីម្ខាងទៀត និងសំណួរនានាធ្វើឡើងដោយក្រុមចៅក្រម"[21]។ វាស្ថិតនៅក្រោមឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូងទាំងស្រុង ក្នុងការមិនយល់ព្រមផ្តល់ទម្ងន់ទៅលើការថ្លែងដែលមិនបានស្បថ និងមិនបានសួរដេញដោល[22]។

១៩- តម្លៃជាភស្តុតាង នៃផ្នែកណាមួយនៃភស្តុតាង គឺជាបញ្ហាដែល "ត្រូវបានធ្វើការវាយតម្លៃផ្តាច់ព្រ័ត្រដោយអង្គជំនុំជម្រះ"[23] ដោយយោងទៅតាមគោលការណ៍ស្តីពីការវាយតម្លៃលើភស្តុតាងដោយសេរីដែលបានឆ្លុះបញ្ចាំងនៅក្នុងវិធាន៨៧ នៃវិធានផ្ទៃក្នុង។ យ៉ាងណាក៏ដោយ ការវាយតម្លៃលើសេចក្តីថ្លែងនានារបស់ ខៀវ សំផន (បើ ខៀវ សំផន នៅតែមិនព្រមឆ្លើយសំណួរជាបន្តទៀត) ត្រូវធ្វើឡើងទៅតាមគោលការណ៍នានាដែលតុលាការ ICTY ធ្លាប់បានអនុវត្តនៅក្នុងការវាយតម្លៃលើការថ្លែងរបស់វិធាន *៨៤ស្ទួន* - បើមិនបានពិសោធទេនោះ សេចក្តីថ្លែងទាំងនោះមិនអាចត្រូវបានផ្តល់ ទម្ងន់ជាភស្តុតាងសំខាន់បានទេ។

---

[21] *រដ្ឋអាជ្ញា ទល់នឹង Fatmir Limaj* និងគូកន, សំណុំរឿងលេខ IT-03-66-A, សាលដីកា, ២៧ កញ្ញា ២០០៧ (អង្គជំនុំជម្រះសាលាឧទ្ធរណ៍) ត្រង់កថាខណ្ឌទី ៧៥។ *រដ្ឋអាជ្ញា ទល់នឹង Jadranko Prlić*, សេចក្តីសម្រេចលើសេចក្តីជូនដំណឹងរបស់មេធាវីការពារក្តីរបស់ Praljak ពាក់ព័ន្ធនឹងសេចក្តីថ្លែងការពារបើកការដេញដោល នៅក្រោមវិធាន៨៤ និង *៨៤ស្ទួន*, ២៧ មេសា ២០០៩ ត្រង់កថាខណ្ឌទី៩ ("*Prlić*")។

[22] សូមអាន, ឧទា. *រដ្ឋអាជ្ញា ទល់នឹង Milan Martić*, សំណុំរឿងលេខ IT-95-11-T, សាលក្រម, ១២ មិថុនា ២០០៧ (អង្គជំនុំជម្រះសាលាដំបូងទី I) ត្រង់កថាខណ្ឌទី២៣។

[23] សំណុំរឿងលេខ ០០១/១៨-០៧-២០០៧/អជសដ, **E188** សាលក្រម ត្រង់កថាខណ្ឌទី ៤២។

២០- សហព្រះរាជអាជ្ញា សូមជូនសេចក្តីសន្និដ្ឋានថា វាគួរតែស្ថិតនៅក្នុងផលប្រយោជន៍នៃមុខងារស្វែងរកការពិតរបស់អង្គជំនុំជម្រះ និងនៅក្នុងផលប្រយោជន៍របស់ជនចាប់ចោទខ្លួនឯង ចំពោះ ខៀវ សំផន ដែលត្រូវបានផ្តល់ប្រឹក្សានៅដំណាក់កាលដំបូងនេះនៃកិច្ចដំណើរការនីតិវិធី ដែលថា សេចក្តីថ្លែងផ្ទាល់មាត់របស់គាត់នៅចំពោះមុខអង្គជំនុំជម្រះ គឺទំនងជាមិនអាចត្រូវបានយល់ព្រមឱ្យទម្ងន់ជាភស្តុតាងដ៏សំខាន់នោះឡើយ ល្គឹកណាតែត្រូវបានដេញដោលតាមរយៈការតាំងសំណួរដោយអង្គជំនុំជម្រះ និងភាគីនានា។

## ខ. ការពិចារណាដោយផ្ទុយគ្នាពីការបដិសេធមិនឆ្លើយសំណួរ
## (Adverse Inferences from a Refusal to Answer Questions)

២១- ដូចដែលបានបញ្ជាក់នៅខាងលើ នៅ អវតក កាលណាជនចាប់ចោទធ្វើសេចក្តីថ្លែងនៅក្នុងអំឡុងពេលនៃកិច្ចដំណើរការផ្តល់ភស្តុតាង ជនជាប់ចោទរូបនោះគឺបានផ្តល់នូវភស្តុតាងយ៉ាងមានប្រសិទ្ធិភាព។ សេចក្តីថ្លែងទាំងនេះគឺមានលក្ខណៈផ្សេងពីសេចក្តីថ្លែងបើក ឬ ថ្លែងបិទការការពារក្តី។ វាត្រូវបានផ្តល់នៅក្នុងរយៈពេលនៃការតាំងសំណួរទៅលើជនជាប់ចោទ ដែលធ្វើឡើងដោយចៅក្រម និងភាគីនានា។ ខណៈដែល (បើមិនបានដេញដោល) វាអាចនឹងបានបន្ថយទម្ងន់ជាភស្តុតាងនោះយ៉ាងណាក៏ដោយក៏វាមានន័យថា សេចក្តីសម្រេចមួយធ្វើឡើងដោយជនជាប់ចោទដើម្បីលះបង់សិទ្ធិរបស់ខ្លួន ក្នុងការស្ថិតនៅស្ងៀមមិននិយាយស្តី និងក្នុងការផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ។

២២- អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY ធ្លាប់បានសម្រេចថា ការពិចារណាដោយផ្ទុយគ្នាអាចនឹងមិនត្រូវបានទាញចេញមកពីការអនុវត្តតាមផ្លូវច្បាប់នូវការប្រើប្រាស់បុព្វសិទ្ធិប្រឆាំងនឹងការធ្វើពិរុទ្ធកម្មប្រឆាំងលើខ្លួនឯងដើម្បីចៀសវាងពីការផ្តល់សក្ខីកម្មអ្វីទាំងអស់នោះឡើយ[24] (an adverse inference may not be drawn from the invocation of the privilege against self-incrimination utilised to avoid testifying at all)។ យ៉ាងណាក៏ដោយ ទាំងតុលាការ ICC និងទាំងទាំងតុលាការ ICTY ធ្លាប់បានសម្រេចថា ខណៈដែលជនជាប់ចោទផ្តល់សក្ខីកម្ម ជនជាប់ចោទរូបនោះ បានលះបង់បុព្វសិទ្ធិក្នុងការធ្វើពិរុទ្ធកម្មប្រឆាំងលើខ្លួនឯង ហើយអាចនឹងមិនយកវាមក

---

[24] *រដ្ឋអាជ្ញា ទល់នឹង Delalić និងគូកន*, សំណុំរឿងលេខ IT-96-21-A, សាលដីកា, ២០ កុម្ភៈ ២០០១ ត្រង់កថាខណ្ឌទី ៧៨១-៧៨៣។

ប្រើមួយចំណែកម្នាក់ (and may not invoke it piecemeal)។ អង្គជំនុំជម្រះសាលាដំបូងមួយរបស់តុលាការ ICC បានថ្លែងថា៖

> *យោងតាមមាត្រា ៦៧(ឋ)(ឆ) នៃច្បាប់លក្ខន្តិកៈ ជនជាប់ចោទមានសិទ្ធិក្នុងការនៅស្ងៀមមិននិយាយស្តី ហើយមិនអាចត្រូវបង្ខំឱ្យផ្តល់សក្ខីកម្មបានឡើយ។ យ៉ាងណាក៏ដោយខណៈដែលជនជាប់ចោទស្ម័គ្រចិត្តផ្តល់សក្ខីកម្មនៅក្រោមសម្បថ ជនជាប់ចោទបានលះបង់សិទ្ធិរបស់ខ្លួនក្នុងការនៅស្ងៀមមិននិយាយស្តី ហើយត្រូវតែឆ្លើយទៅនឹងគ្រប់សំណួរពាក់ព័ន្ធទាំងអស់ សូម្បីតែចម្លើយរបស់គាត់ជាចម្លើយដាក់ពិរុទ្ធកម្មក៏ដោយ។ ដូច្នេះសក្ខីកម្មរបស់ជនជាប់ចោទអាចនឹងត្រូវបានប្រើធ្វើជាភស្តុតាងប្រឆាំងនឹងគាត់នៅក្នុងករណីរឿងបច្ចុប្បន្ន។*
> ***លើសពីនេះទៀត បើគាត់បដិសេធមិនឆ្លើយទៅនឹងសំណួរណាមួយ ដែលគេបានអនុញ្ញាតឱ្យសួរ អង្គជំនុំជម្រះអាចនឹងទាញចេញនូវការពិចារណាដោយផ្ទុយ ណាមួយតាមការសមស្រប[25] (the Chamber may draw any adverse inferences as appropriate)***។

២៣- ស្រដៀងគ្នានេះដែរ អង្គជំនុំជម្រះសាលាដំបូងមួយរបស់ តុលាការ ICTY បានថ្លែងថា៖

> *វិសាលភាព [សិទ្ធិរបស់ជនជាប់ចោទដែលត្រូវបានការការពារប្រឆាំងនឹងការធ្វើពិរុទ្ធកម្មលើខ្លួនឯង] ត្រូវបានកម្រិត។ យោងទៅតាមច្បាប់លក្ខន្តិកៈ ជនជាប់ចោទអាចនឹងមិនត្រូវបានបង្ខំឱ្យផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯង ឬ ឱ្យឆ្លើយសារភាពពីពិរុទ្ធភាពទេ។ បន្ថែមលើនេះ ជនជាប់ចោទគឺមិនស្ថិតនៅក្រោមកាតព្វកិច្ចជាទូទៅក្នុងការបង្ហាញឯកសារដែលមាននៅក្នុងការកាន់កាប់របស់ខ្លួន ជូនទៅអយ្យការ ឬ អង្គជំនុំជម្រះសាលាដំបូងទេ។ យ៉ាងណាក៏ដោយ ផលវិបាកកិច្ចដំណើរការនីតិវិធីមួយចំនួនអាចនឹងលេចចេញមកពីជំហរកិច្ចដំណើរការនីតិវិធីដែលជនជាប់ចោទបានប្រកាន់យក។ ជាឧទាហរណ៍ **ខណៈដែលជនជាប់ចោទណាម្នាក់បានសម្រេចថាប្រកាន់ជំហរឡើងធ្វើជាសាក្សី គាត់ត្រូវស្ថិតនៅក្រោម***

[25] *រដ្ឋអាជ្ញា ទល់នឹង Katanga និង Chui*, សំណុំរឿងលេខ ICC-01/04-01/07, សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តីឱ្យ Mathieu Ngudjolo, ២០ កុម្ភៈ ២០០១ ត្រង់កថាខណ្ឌទី ៧៨១-៧៨៣។ សុំឱ្យបានទទួលការធានាទាក់ទងនឹងការធ្វើពិរុទ្ធកម្មប្រឆាំងនឹងខ្លួនឯងសម្រាប់ជនជាប់ចោទ, ១៣ កញ្ញា ២០១១, ត្រង់កថាខ័ណ្ឌ៧, ៨។

***ការតព្វកិច្ចឆ្លើយទៅនឹងសំណួរនានា សូម្បីតែចម្លើយរបស់គាត់អាចជាចម្លើយដាក់ពិរុទ្ធកម្មលើខ្លួនឯងក៏ដោយ***[26] ។

២៤- គេគ្មានបទប្បញ្ញត្តិសម្រាប់ជនជាប់ចោទដែលត្រូវធ្វើសម្បថនៅចំពោះមុខ អ.វ.ត.ក ទេ។ យ៉ាងណាមិញ ដូចបានបង្ហាញខាងលើ ជំហររបស់ ខៀវ សំផន គឺស្រដៀងគ្នានឹងជនជាប់ចោទដែលបានជ្រើសយកដោយស្ម័គ្រចិត្តដើម្បីឆ្លើយបំភ្លឺ ហើយបានធ្វើសម្បថនៅចំពោះមុខតុលាការ ICTY/ICC ។

២៥- នៅក្នុងស្ថានភាពនេះ ការបដិសេធរបស់ ខៀវ សំផន មិនឆ្លើយតបទៅនឹងសំណួរផ្សេងៗ (បើសិនជាគាត់បដិសេធមិនឆ្លើយនឹងសំណួរនៅក្នុងដំណាក់កាលណាមួយនៃកិច្ចដំណើរការនីតិវិធី) អាចនាំទៅដល់ការពិចារណាជាអវិជ្ជមានក្នុងការវាយតម្លៃលើភ័ស្តុតាងប្រឆាំងនឹងរូបគាត់ ហើយសហព្រះរាជអាជ្ញាមានចេតនាចង់ធ្វើការសន្និដ្ឋានទៅលើផលប៉ះពាល់នេះនៅពេលបិទការជំនុំជម្រះនេះ។ អាស្រ័យហេតុនេះ វាជាការសមស្របដែលជនជាប់ចោទត្រូវតែបានជូនដំណឹងក្នុងពេលឥឡូវនេះ ដូចដែលគាត់បានជ្រើសរើសក្នុងការឆ្លើយតបទៅនឹងសំណួរផ្សេងៗ ហើយការបដិសេធណាមួយអាចនឹងមានផលវិបាកដល់រូបគាត់ដែលផ្ទុយពីអ្វីដែលគាត់ចង់បាន។

## **សំណើ**

២៦- ដោយសារមូលហេតុដូចបានរៀបរាប់ខាងលើ សហព្រះរាជអាជ្ញាសូមស្នើដល់អង្គជំនុំជម្រះ ជូនដំណឹងដល់ជនជាប់ចោទថា បើសិនជាគាត់បដិសេធមិនឆ្លើយនឹងសំណួរនៅពេលជំនុំជម្រះ :

(ក) ចម្លើយផ្ទាល់មាត់របស់គាត់នៅចំពោះមុខអង្គជំនុំជម្រះ ទំនងជានឹងមិនស្របទៅនឹងទម្ងន់នៃភ័ស្តុតាងសំខាន់ៗទេ; ហើយ

[26] *ដដែលដូចខាងលើ,* កថាខ័ណ្ឌទី១-២។ *រដ្ឋអាជ្ញា ទល់នឹង Gotovina នឹងគូកន.,* សំណុំរឿងលេខ IT-06-90-T, សេចក្តីសម្រេចលើពាក្យសុំរួមរបស់មេធាវីការពារក្តីសុំឱ្យហាមឃាត់ការប្រើប្រាស់ឯកសាររបស់មេធាវីការពារក្តីដោយការិយាល័យអយ្យការ, ៥ ធ្នូ ២០០៨, ត្រង់កថាខ័ណ្ឌទី៩ (កំណត់សំគាល់ចុងទំព័រត្រូវបានលុបចេញ)។

(ខ) អង្គជំនុំជម្រះអាចទាញយកការពិចារណាអវិជ្ជមានចេញពីការបដិសេធដូច្នេះ ក្នុងការវាយតម្លៃអំពីភ័ស្តុតាងនៅលើបញ្ហានៃការពាក់ព័ន្ធ និងការទទួលខុសត្រូវរបស់គាត់ ចំពោះឧក្រិដ្ឋកម្មដូចបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយ។

២៧- ជាចុងក្រោយ ដើម្បីជាផលប្រយោជន៍នៃការគ្រប់គ្រងសវនាការឲ្យមានរបៀបរៀបរយ និងត្រឹមត្រូវយុត្តិធម៌ដល់គូភាគីទាំងអស់ សហព្រះរាជអាជ្ញាសូមស្នើអង្គជំនុំជម្រះបង្គាប់ ខៀវ សំផន ឲ្យនិយាយនៅពេលឥឡូវនេះ ១) ថាតើគាត់មានចេតនាឆ្លើយនឹងសំណួរផ្សេងៗដែរក៏អត់ និង ២) បើសិនជាគាត់មានចេតនាឆ្លើយនឹងសំណួរ ថាតើគាត់នឹងធ្វើនៅពេលវគ្គសវនាការនិមួយៗ ឬគ្រាន់តែនៅចុងបញ្ចប់នៃកិច្ចដំណើរការនីតិវិធី គឺនៅពេលដែលភ័ស្តុតាងត្រូវបានបង្ហាញនៅគ្រប់វគ្គ និងដំណាក់កាលទាំងអស់នៃការជំនុំជម្រះ៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១២ | **លោក យ៉េត ចរិយា**<br>សហព្រះរាជអាជ្ញារង | ភ្នំពេញ | |
| | **លោក** Andrew CAYLEY<br>សហព្រះរាជអាជ្ញា | | |